ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១៣៥ សហវ.ប្រក

## ប្រកាសអន្តរក្រសួង

## ស្តីពី

## ការបង្កើតក្រុមការងារទទួលបន្ទុកលើការងារគ្រប់គ្រងមន្ទីរពេទ្យកន្ធបុប្ផា

## របស់

## ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសុខាភិបាល
- យោងតម្រូវការចាំបាច់នៃការងារ

## សម្រេច

**ប្រការ១:** ត្រូវបានបង្កើតក្រុមការងារទទួលបន្ទុកលើការងារគ្រប់គ្រងមន្ទីរពេទ្យគន្ធបុប្ផា ដូចមានរាយនាមខាងក្រោម÷

១. លោកជំទាវ **ឌួន សុខា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធាន

២. ឯកឧត្តម **តែ គុយស៊ាង** រដ្ឋលេខាធិការ ក្រសួងសុខាភិបាល អនុប្រធាន

៣. ឯកឧត្តម **យឹត ស៊ុនណារ៉ា** អនុរដ្ឋលេខាធិការ ក្រសួងសុខាភិបាល អនុប្រធាន

៤. ឯកឧត្តម **ចាន់ សុធី** អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធាន

៥. លោកជំទាវ **យក់ សម្បត្តិ** អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល+ហិរញ្ញវត្ថុក្រសួងសុខាភិបាល អនុប្រធាន

៦. លោកជំទាវ **ឱ វណ្ណឌីន** អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេសក្រសួងសុខាភិបាល អនុប្រធាន

៧. ឯកឧត្តម **ផាន់ ផល្លា** អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

៨. លោក **ញឹម ខេមរា** អគ្គនាយករងនៃអគ្គនាយកដ្ឋានថវិកាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

៩. លោក **ហាច រតនៈ** ប្រធាននាយកដ្ឋានថវិកានីយកម្មក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

១០. លោក **អ៊ិន មាត្រា** ប្រធាននាយកដ្ឋានធានារ៉ាប់រង និងសោធន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

១១. លោក **មុំ សំបូរ** ប្រធាននាយកដ្ឋានគ្រប់គ្រងបុគ្គលិកក្រសួងសុខាភិបាល សមាជិក

១២. លោក **សុខ ស្រ៊ុន** ប្រធាននាយកដ្ឋានមន្ទីរពេទ្យក្រសួងសុខាភិបាល សមាជិក

១៣. លោក **គី សន់នី** ប្រធានមន្ទីរពេទ្យគន្ធបុប្ផា សមាជិក

១៤. លោក **យ៉ៃ ចន្ទនា** ប្រធានមន្ទីរពេទ្យជ័យវរ្ម័នទី៧ សមាជិក

១៥. លោក **ស្រី ទុច** អនុប្រធាននាយកដ្ឋានហិរញ្ញកិច្ចក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

១៦. លោក **ហ៊ិញ ឫទ្ធីពល** អនុប្រធាននាយកដ្ឋានថវិកានីយកម្មក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

**ប្រការ២:** ក្រុមការងារនេះ មានតួនាទី និងភារកិច្ច ដូចតទៅ÷

១-ធ្វើការងារជាមួយលោកវេជ្ជបណ្ឌិត Beat Richner និងមន្ត្រីពាក់ព័ន្ធនៃមន្ទីរពេទ្យគន្ធបុប្ផា ដើម្បីទទួលព័ត៌មាន និងសិក្សាលើទិដ្ឋភាពហិរញ្ញវត្ថុ,ប្រតិបត្តិការ,សេវាសុខាភិបាល និងនីតិវិធីនៃការគ្រប់គ្រងរបស់មន្ទីរពេទ្យ

២-សិក្សាលើបញ្ហាហិរញ្ញប្បទាននៃមូលនិធិគន្ធបុប្ផា ដើម្បីធានាចីរភាពនៃដំណើរការជាប្រចាំរបស់មន្ទីរពេទ្យនៅថ្ងៃអនាគត ដោយផ្អែកលើគោលការណ៍នៃស្តង់ដារសេវាសមស្រប និងប្រសិទ្ធភាព

៣-រៀបចំយន្តការនៃការគ្រប់គ្រង និងកិច្ចដំណើរការរបស់មន្ទីរពេទ្យ នៅពេលដែលរាជរដ្ឋាភិបាលទទួលយកមន្ទីរពេទ្យនេះមកគ្រប់គ្រងវិញ ដើម្បីឱ្យមន្ទីរពេទ្យនេះក្លាយជាមន្ទីរពេទ្យរដ្ឋដែលមានស្តង់ដារគំរូនាពេលអនាគត។

**ប្រការ៣:** ក្រុមការងារទទួលបន្ទុកលើការងារគ្រប់គ្រងមន្ទីរពេទ្យគន្ធបុប្ផា ប្រើប្រាស់អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាលេខាធិការដ្ឋាន។

**ប្រការ៤:** សមាជិកក្រុមការងារទទួលបន្ទុកលើការងារគ្រប់គ្រងមន្ទីរពេទ្យគន្ធបុប្ផា ត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធាន ឬ អនុប្រធាន (តាមការចាត់តាំងរបស់ប្រធាន) ករណីប្រធានអវត្តមាន។

**ប្រការ៥:** ប្រធានគណៈកម្មាធិការទទួលបន្ទុកលើការងារគ្រប់គ្រងមន្ទីរពេទ្យគន្ធបុប្ផា និងសាមីខ្លួន ដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ ២០១៦

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**ម៉ម_ប៊ុនហេង**

**កន្លែងទទួល:**

- ស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ